**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: ០៤៤ ឧ.វ.ប.ន.វិលាក.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ស្តង់ដារកម្ពុជា
# ផ្នែកផលិតផលគ្រឿងសម្អាង ចំនួន៤ស្តង់ដារ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣



៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ នៃច្បាប់ស្តីពីស្តង់ដារកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញប្រកាសលេខ ០៦៣ ឧវបន.វសក.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ ស្តីពីសមាសភាពក្រុមប្រឹក្សាស្តង់ដារជាតិ
- បានឃើញសេចក្តីសម្រេចលេខ ០៧៣ ឧវបន.វសក.សសរ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ ស្តីពីសមាសភាពគណៈកម្មការបច្ចេកទេសទី៩ (គ.ប.៩) ផ្នែកផលិតផលគ្រឿងសម្អាង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

កំណត់ទទួលយកទាំងស្រុងនូវស្តង់ដារអន្តរជាតិ (ISO) ផ្នែកផលិតផលគ្រឿងសម្អាង ចំនួន៥(ប្រាំ) ជាស្តង់ដារកម្ពុជាសម្រាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា មានឈ្មោះដូចខាងក្រោមៈ

| ល.រ | លេខស្តង់ដារ | ឈ្មោះស្តង់ដារជាភាសាអង់គ្លេស | ឈ្មោះស្តង់ដារជាភាសាខ្មែរ |
|---|---|---|---|
| ១ | CS ISO 4973:2024 (IDT/ED 2023) | Cosmetics — Microbiology — Quality control of culture media and diluents used in cosmetics standards | គ្រឿងសម្អាង — អតិសុខុមជីវសាស្ត្រ — ការគ្រប់គ្រងគុណភាពនៃមជ្ឈដ្ឋានបណ្តុះ និងសារធាតុពង្រាវ ដែលត្រូវប្រើប្រាស់ក្នុងស្តង់ដារគ្រឿងសម្អាង |
| ២ | CS ISO 1930:2019 /Amd.1:2024 (IDT/ED 2022) | Cosmetics — Microbiology — Evaluation of the antimicr obial protection of a cosmetic product | គ្រឿងសម្អាង — អតិសុខុមជីវសាស្ត្រ — ការវាយតម្លៃផលិតផលគ្រឿងសម្អាងលើការការពារប្រឆាំងនឹងអតិសុខុមប្រាណ |
| ៣ | CS ISO 8415:2017 /Amd.1:2024 (IDT/ED 2022) | Cosmetics — Microbiology — Detection of specified and non-specified microorganisms | គ្រឿងសម្អាង — អតិសុខុមជីវសាស្ត្រ — ការកំណត់រកអតិសុខុមប្រាណយថាប្រភេទ និងអតិសុខុមប្រាណអយថាប្រភេទ |
| ៤ | CS ISO 1148:2024 (IDT/ED 2017) | Cosmetics — Microbiology — General instructions for microbiological examination | គ្រឿងសម្អាង — អតិសុខុមជីវសាស្ត្រ — ការណែនាំទូទៅសម្រាប់ការពិនិត្យអតិសុខុមជីវសាស្ត្រ |

**ប្រការ២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ ._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**និងជាប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ**

**ហែម វណ្ណឌី**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ